# សង្កេតទំនៀមខ្លះក្នុងជំនឿពាក់ព័ន្ធនឹងទឹកភ្លៀង

ភ្លៀងជាកង្វល់ធំរបស់ "អ្នកស្រែ" ដែលតែងត្រូវការចាំបាច់សម្រាប់ឱ្យដំណាំផ្សេងៗដុះរស់លូតលាស់ល្អ។ ជំនឿ និងទំនៀមទាក់ទងនឹងទឹកភ្លៀងនៅក្នុងសង្គមខ្មែរ គេសង្កេតឃើញប្រារព្ធតាំងពីរាស្ត្រសាមញ្ញរហូតដល់ព្រះមហាក្សត្រ ដើម្បីចង់ដឹងពីស្ថានភាពភ្លៀងប្រចាំឆ្នាំ ឬបួងសួងឱ្យភ្លៀងធ្លាក់មកគ្រប់គ្រាន់ មិនរាំងស្ងួត ឬមិនជន់លិចលង់ភូមិស្រុកជាដើម។ បើរៀបរាប់ដោយត្រួសៗមានព្រះរាជពិធី ឬពិធីខ្លះខ្មែរស្គាល់ជាទូទៅដូចជា ព្រះរាជពិធី និងពិធីសំពះព្រះខែ ប្រារព្ធនៅខែកត្តិក និងព្រះរាជពិធីច្រត់ព្រះនង្គ័លប្រារព្ធនៅខែពិសាខជាដើម។ ប៉ុន្តែនៅតាមភូមិស្រុកមួយចំនួនទៀត មានទំនៀមក្នុងជំនឿពាក់ព័ន្ធនឹងកង្វល់អំពីទឹកភ្លៀងដែរដូចជា រាំត្រុដិនាងម៉េវ ឆ្លងបេត្រ ទាញព្រ័ត្រថ្វាយអ្នកតា ឆាន់សុំទឹកភ្លៀង ចាក់ត្រពោករាហូ ទេសន៍មហាជាតក៍...ប្រារព្ធចាប់ពីរវាងចូលឆ្នាំរួចរហូតដល់ខែពិសាខ ឬខែជេស្ឋ ដែលទុកជាដើមឆ្នាំ។

**តំបន់អង្គរ "ចាក់ត្រពោករាហូ"**

ទំនៀមពាក់ព័ន្ធនឹងទឹកភ្លៀងប្រារព្ធនៅតំបន់អង្គរមានច្រើនបែបណាស់។ អ្នកស្រុកតែងរៀបចំប្រារព្ធនៅបុរាណដ្ឋានមួយចំនួនដូចជា ប្រាសាទប្រែរូប ប្រាសាទមេបុណ្យខាងកើត ប្រាសាទបន្ទាយសំរែ ប្រាសាទលាក់នាង និងប្រាសាទនាគព័ន្ធជាដើម ហើយភាគច្រើនពុំធ្វើទៀងទាត់រាល់ឆ្នាំឡើយ។[១] ចំពោះពិធីពាក់ព័ន្ធនឹងជំនឿសុំទឹកភ្លៀងនៅប្រាសាទនាគព័ន្ធ ឬពាក្យអ្នកស្រុកហៅថា "ចាក់ត្រពោករាហូ" តែងធ្វើក្រោយ "ឆ្លងបេត្រ"[២] ជាពិសេសក្នុងករណីចូលដល់រដូវដកស្ទូង តែភ្លៀងពុំធ្លាក់មកគ្រប់គ្រាន់។ គេប្រារព្ធពិធីប្រារពីរថ្ងៃនៅក្នុងបរិវេណប្រាសាទនាគព័ន្ធផ្ទាល់ ដោយមានកិច្ចពិធីភ្ជាប់នឹងព្រះពុទ្ធសាសនាផង។ ក្នុងវេលារសៀលថ្ងៃទី១ គេធ្វើកិច្ចប្រុងពាលី ឆាកហោរលើកទង់ ព្រមទាំងធ្វើកិច្ចបួងសួង សូត្រប្រកាសយាងអស់ទេវតា និងអញ្ជើញអ្នកតានៅតាមប្រាសាទជុំវិញ (រូបលេខ១-២)។

---

[១] សូមអាន "ពិធីសុំទឹកភ្លៀងអ្នកតំបន់អង្គរ" ដោយ សុខ កែវណ្ណារ៉ា ផ្សាយលើគេហទំព័រ https://ams.com.kh/khmercivilization/detail/1356 និង "ពិធីសុំទឹកភ្លៀង" ដោយ សាម ច័ន្ទវីរៈ ផ្សាយលើគេហទំព័រ https://www.yosothor.org/publications/khmer-renaissance/chapter-two/phity-som-terk-pleang.html

[២] សូមអាន "ឆ្លងបេត្រ" ដោយ អាំង ជូលាន ២០១០-២០១១, លេខ៦, ទំ.៣២-៣៥។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ១ កិច្ចបួងសួងនៅប្រាង្គកណ្តាលនៃប្រាសាទនាគព័ន្ធ (រូបថត៖ អាជ្ញាធរជាតិអប្សរា)



រូបលេខ២ គ្រឿងរណ្តាប់ថ្វាយនៅប្រាង្គកណ្តាលប្រាសាទ

បន្ទាប់ពីចប់កិច្ចប្រុងពាលី សូត្របួងសួងប្រកាសទេវតា គេរៀបចំកិច្ចនមស្ការព្រះរត្នត្រៃ ព្រមទាំងនិមន្តព្រះសង្ឃសូត្រចម្រើនព្រះបរិត្តជ័យមង្គល។ លុះចប់អំពីនោះមក គឺជាកិច្ចបញ្ចូលរូបសុំទឹកភ្លៀង និងសុំសេចក្តីសុខ ដែលជាកិច្ចសំខាន់ក្នុងពិធីខាងលើ (រូបលេខ៣)។ ក្នុងពេលបញ្ចូលរូប មានស្នំម្នាក់ ឬពីរនាក់តែងចូលមកអែបជិតរូបស្នង។ ស្នំមាននាទីពាំនាំកង្វល់របស់អ្នកស្រុក និងជាពិសេសសាកសួរអំពីទឹកភ្លៀង។

លុះចប់កិច្ចបញ្ចូលបញ្ចាន់ នៅវេលាព្រឹកថ្ងៃទី២ គេរៀបចំប្រគេនចង្ហាន់ព្រះសង្ឃ និងរាប់បាត្រ។ បន្ទាប់មកគឺជាកិច្ចចាក់ត្រពោករាហូ ដង្ហែប្រទក្សិណជុំវិញមាត់ស្រះធំនៃប្រាង្គកណ្តាល ជាកិច្ចបញ្ចប់។ ក្នុងឱកាសនេះ ព្រះសង្ឃទាំងឡាយគង់ក្នុងរោងពិធីសូត្រធម៌ “មហាមេឃ” ដែលគេជឿថាជាធម៌សុំទឹកភ្លៀង។ រីឯអាចារ្យ ដឹកនាំអ្នកភូមិក្មេងចាស់ស្រីប្រុស ដើរប្រទក្សិណបីជុំមាត់ស្រះ រួចចាក់ទឹកតាមមាត់រន្ធទាំង៤ទិស ដើម្បីឱ្យទឹកហូរចុះតាមមាត់ទនីមួយៗ ដែលមានមាត់មនុស្ស និងសត្វ ហូរឆ្ពោះទៅកាន់កូនស្រះតូចៗជុំវិញៗ។ រូបភាពនេះ គេសន្មតថាជានិមិត្តរូបទឹកសម្បូរហូរហៀរហើយ។ មិនតែប៉ុណ្ណោះ គេឃើញអ្នកស្រុកក្មេងចាស់លេងជះទឹកដាក់គ្នាទៅវិញទៅមក ខ្លះច្រៀង ខ្លះរាំ សប្បាយ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ភ្លាកភ្លាយ ហាក់ដូចជាកំពុងសាទរភ្លៀងធ្លាក់មកមែនៗ ដោយឡែក ពិធីក្នុងឆ្នាំនេះ គេសង្កេតឃើញមានរាំត្រុដិ និងហែនាងម៉េវផងដែរ។



រូបលេខ២៣ កិច្ចបញ្ចូលរូបស្នងសុំទឹកភ្លៀង



រូបលេខ២៤ អ្នកភូមិយកទឹកចាក់ចូលតាមរន្ធបង្ហូរនៃមាត់មនុស្ស និងសត្វនីមួយៗ

### តំបន់ប្រាសាទសំបូរព្រៃគុក "ច្រត់ព្រះនង្គ័ល"

ចំពោះទំនៀមពាក់ព័ន្ធនឹងភ្លៀងនៅតំបន់ប្រាសាទសំបូរព្រៃគុក តែងតែប្រារព្ធក្នុងរវាងខែពិសាខហៅថា "ច្រត់ព្រះនង្គ័ល" ដើម្បីបើករដូវធ្វើស្រែ។ ទំនៀមនេះមិនកំណត់ថ្ងៃទេ តែគេប្រកាន់យកថ្ងៃអង្គារ និងថ្ងៃសៅរ៍ នៃវេលាដើមខ្នើត នៅមុខខ្ទមអ្នកតា។ ប៉ុន្តែថ្វីបើកិច្ចសំខាន់ហៅថាច្រត់ព្រះនង្គ័លក៏ពិតមែន តែគេពុំមាននង្គ័ល ឬសកម្មភាពអ្វីសម្គាល់ថាជាកាភ្ជួរ ដូចព្រះរាជពិធីច្រត់ព្រះនង្គ័លរបស់ព្រះមហាក្សត្រឡើយ។ ក្នុងថ្ងៃនោះ អ្នកស្រុកដែលទៅចូលរួមតែងនាំគ្នាទៅដកដើមសណ្តែកព្រៃ យកទៅដោតមួយគូម្នាក់ជុំវិញរោងអ្នកតា ដោយសម្គាល់ហៅថា "ដាំដើមព្រះភូមិ" (រូបលេខ២៥)។ រីឯរណ្តាប់សំខាន់មួយផ្សេងទៀតគឺ "ព្រលឹងស្រូវ" ដែលធ្វើពីលាជ ហើយដោតនៅលើនំនាល (រូបលេខ២៦)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៥ អ្នកស្រុកនាំគ្នាយកដើមសណ្ដែកព្រៃថ្វាយអ្នកតា



រូបលេខ៦ ព្រលឹងស្រូវដែលធ្វើពីលាជ សម្រាប់ថ្វាយក្នុងខ្ទមអ្នកតា

ក្នុងពិធីនេះមានមនុស្សម្នាក់ហៅថា "ជម្នឿង" ដែលជាអ្នករៀបចំកិច្ចសំខាន់ដូចជាកិច្ចសែនព្រេនអ្នកតា និងធ្វើកិច្ចបញ្ជូនជាដើម។[៣] កិច្ចសំខាន់ចុងក្រោយ គឺជម្នឿងដឹកនាំអ្នកភូមិទៅដុសរំអិលថ្ម (ថ្មជណ្ដើរប្រាសាទសំបូរព្រៃគុក) ដើម្បីយកមកមកចឹមលើថ្វាសក្មេងៗ ដើម្បីសុំសេចក្ដីសុខ ពិសេសចៀសផុតពីរន្ទះបាញ់ក្នុងរដូវភ្លៀង។[៤]

## ព្រះរាជពិធីច្រត់ព្រះនង្គ័ល

ក្នុងព្រះរាជពិធីទ្វាទសមាស ព្រះរាជពិធីច្រត់ព្រះនង្គ័លក្នុងសង្គមខ្មែរតែងប្រារព្ធជាប្រក្រតី ចាប់ពីថ្ងៃ១រោច ដល់ថ្ងៃ៤រោច ខែពិសាខ។ ពីថ្ងៃ១រោច ដល់ថ្ងៃ៣រោច ក្រុមបាគូតែងធ្វើកិច្ចជាប្រចាំតាមទំនៀមនៅទីព្រះស្រែ។[៥] លុះដល់ថ្ងៃ៤រោច ព្រះមហាក្សត្រទ្រង់តាំងមន្ត្រីជាន់ខ្ពស់ណាម្នាក់ឱ្យធ្វើជាស្ដេចមាឃ ហើយភរិយាធ្វើជាមេហួ ដោយយកមុក្រអូបមកចឹមលើថ្ងាសជាកិច្ចសន្មត ចេញច្រត់ព្រះនង្គ័ល។[៦] ក្នុងព្រះរាជពិធីច្រត់ព្រះ

[៣] ក្នុងកិច្ចបញ្ជូននេះ គេតែងធ្វើរូបរទេះគោ រទេះក្របីដំរី សេះ គោ និងមាន់ក្ដាង រួចដង្ហែយកទៅដាក់នៅស្រែណាមួយក្នុងទិសខាងត្បូងខ្ទមអ្នកតា ដោយរណ្ដាប់ទាំងនោះសន្មត់ជាក្បួនទ័ពទៅបណ្ដេញខ្មោចព្រៃកុំឱ្យមកបៀតបៀនរាតត្បាតដល់ភូមិស្រុក។

[៤] សូមអាន "ច្រត់ព្រះនង្គ័ល" ដោយ សាន់ ស៊ីថុន ផ្សាយលើតំណ https://www.yosothor.org/publications/khmer-renaissance/chapter-two/chrot-phreas-neang-kol.html

[៥] ឈឹម ក្រសេម និង ចាប ពិន ១៩៥១: ៨១-៨៧

[៦] ពេជ្រ សល់ ១៩៦៦: ៣២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

នង្គ័លនេះ តែងមានកិច្ចផ្សងគោឧសភរាជ ដើម្បីឱ្យដឹងអំពីផលដំណាំផ្សេងៗនិងទឹកភ្លៀង សម្រាប់រដូវកាលធ្វើកសិកម្មថ្មី។ វត្ថុដែលយកទៅផ្សងនឹងគោឧសភរាជនោះមានប្រាំពីរមុខគឺ ស្រូវ ពោត សណ្តែក ល្ង ស្មៅ ទឹក និងស្រា។ ប្រសិនបើគោឧសភរាជបរិភោគគ្រាប់ពូជណាមួយ ទំនាយថាដំណាំនោះនឹងបានផលល្អ ហើយបើគោឧសភរាជបរិភោគទឹក ទំនាញថានឹងមានភ្លៀងធ្លាក់បរិបូរណ៍។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើគោឧសភរាជបរិភោគស្មៅស្រស់ នោះទំនាយថាស្រុកទេសនឹងកើតមានជំងឺលើសត្វពាហនៈ។ បើគោឧសភរាជបរិភោគស្រា ទំនាយថាស្រុកទេសនឹងកើតមានមនុស្សពាល ចោរលួចឆក់ប្លន់ និងអសន្តិសុខក្នុងសង្គម (រូបលេខ៧)។



រូបលេខ៧ ការផ្សងគោឧសភរាជក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័លនៅទីព្រះស្រែ (វាលព្រះមេរុ)

## ព្រះរាជពិធីអកអំបុក "ផ្សងទៀន"

ក្រៅពីព្រះរាជពិធីដែលជាទំនៀមពាក់ព័ន្ធនឹងទឹកភ្លៀង ប្រារព្ធក្នុងខែពិសាខដើមឆ្នាំដូចរៀបរាប់ខាងលើ គឺព្រះរាជពិធីអកអំបុកប្រារព្ធចុងឆ្នាំ ក្នុងកិច្ចផ្សងទៀន ក៏មានអត្ថន័យក្នុងជំនឿទឹកភ្លៀងដែរ។ បើគិតតាមប្រតិទិនចន្ទគតិ គឺពីថ្ងៃ១៤-១៥កើត ដល់ថ្ងៃ១រោច

ខែកត្តិក កំណត់ជា "ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក"។ នៅក្នុងព្រះបរមរាជវាំង ព្រះមហាក្សត្រស្តេចផែនដីជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់តែងយាងជាព្រះរាជាធិបតី ជាពិសេសនៅក្នុងព្រះរាជពិធីសំពះព្រះខែ អកអំបុក ដែលមានទំនៀមសម្រក់ទៀនផ្សងទឹកភ្លៀងសម្រាប់ព្រះនគរ។

ក្រុមបាគូនៃព្រះរមរាជវាំង តែងរៀបចំចាត់ចែងអុជទៀនបិទលើទម្រូបនាគ ទៅតាមចំនួនរាជធានី និងខេត្តទាំងអស់ក្នុងទូទាំងប្រទេស។ លុះរៀបចំស្រេចហើយ ទើបធ្វើកិច្ចនមស្ការព្រះរតនត្រៃ និងបួងសួងអញ្ជើញទេព្តានៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ។ ផុតពីនោះ ទើបផ្តើមអុជទៀនទាំងអស់ព្រមគ្នាឡើង ហើយទៀននីមួយៗស្រក់ចុះមក គឺតំណាងទឹកភ្លៀងតាមខេត្តនីមួយៗ ដែលយកបរិមាណក្រមួនទៀនស្រក់ ផ្សងជាទឹកភ្លៀងដើមឆ្នាំ កណ្តាលឆ្នាំ និងចុងឆ្នាំ។ បើទៀនតំណាងរាជធានី ឬខេត្តណាស្រក់ច្រើនពីដំបូងនោះទំនាយថារាជធានី ឬខេត្តនោះនឹងមានភ្លៀងធ្លាក់ច្រើននៅដើមឆ្នាំ។ ប៉ុន្តែបើទៀនតំណាងរាជធានីឬខេត្តណាស្រក់តិច ទំនាយថានឹងទទួលបានទឹកភ្លៀងតិច(រូបលេខ៨)។



*រូបលេខ៨ ព្រះមហាក្សត្រគង់ជាព្រះរាជាធិបតីក្នុងព្រះរាជពិធីសំពះព្រះខែ អកអំបុក និងសម្រក់ទៀនផ្សងទឹកភ្លៀង (រូបថត៖ **pressocm.gov.kh**)*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

*អត្ថបទ៖ សង្កេតទំនៀមខ្លះក្នុងជំនឿពាក់ព័ន្ធនឹងទឹកភ្លៀង*

ដោយឡែក ចំពោះពិធីសំពះព្រះខែ អកអំបុក អ្នកស្រុកខ្លះហៅដោយខ្ចីក្នុងន័យរួមថា "បុណ្យអកអំបុក" ឬ "បុណ្យមហាអំបុក"[៧] ឬអ្នកស្រុកភាគខាងជើងហៅថា "អកព្រះខែ" ឬ "បង្អកព្រះខែ"ៗ[៨] នៅតាមស្រុកភូមិ ពិធីនេះច្រើនតែដឹកនាំប្រារព្ធដោយអាចារ្យនិងចាស់ទុំ ហើយគេសង្កេតឃើញរបៀបធ្វើប្លែកគ្នាតាមតំបន់ៗ ជាទូទៅគេច្រើនរៀបចំអំបុក ចេក ដូង ដំឡូង ត្រាវ អំពៅ និងវណ្ណាប់ផ្សេងៗទៀតដាក់តុ អុជទៀនធូប សូត្រប្រកាសឧទ្ទិសថ្វាយព្រះចន្ទ្រៗបន្ទាប់មកគេបង្អកអំបុកបញ្ចុកចេកគ្នាទៅវិញទៅមកយ៉ាងសប្បាយរីករាយ រវាងស្រីប្រុសទាំងឡាយដែលចូលរួមក្នុងពិធីៗ ផុតពីនោះមក ទើបគេធ្វើកិច្ចសម្រក់ទៀនផ្សងទឹកភ្លៀង ឬគេធ្វើកិច្ចផ្សងទឹកភ្លៀងមុនក៏មានៗ លទ្ធផលនៃទៀនស្រក់ចុះមក គឺតំណាងទឹករបបទឹកភ្លៀងដូចលំនាំព្រះរាជពិធីក្នុងព្រះបរមរាជវាំងដែរៗ

ប៉ុន្តែទោះបីជាយ៉ាងណាក្តី ក្រៅពីពិធី និងព្រះរាជពិធី គឺនៅមានពិធីជាទំនៀមរបស់អ្នកស្រុកផ្សេងៗទៀត ប្រារព្ធឡើងក្នុងជំនឿសុំទឹកភ្លៀងដែរៗ បើរាប់ដោយសង្ខេបពិធីទាំងនោះមានដូចជា ទាញព្រ័ត្រឆ្លងចេត្រនៅស្ពានកំពង់ក្តី[៩] ទាញព្រ័ត្រឫស្សីសុំទឹកភ្លៀងនៅសំបូរព្រៃគុក[១០] សុំទឹកភ្លៀងនៅប្រាសាទលាក់នាង[១១] សុំទឹកភ្លៀងនៅកំពង់ចាម[១២] សម្តែងល្ខោនខោលនៅវត្តស្វាយអណ្តែត[១៣] ទាញព្រ័ត្រថ្វាយអ្នកតាដើមសំរោង[១៤] នៅខេត្តកណ្តាល និងទំនៀមទេសន៍មហាជាតក៏ជាដើមៗ

ដូច្នេះជារួមមក ទំនៀមពាក់ព័ន្ធនឹងជំនឿអំពីទឹកភ្លៀង តែងប្រារព្ធធ្វើទាំងព្រះមហាក្សត្រ រហូតដល់ប្រជារាស្ត្រសាមញ្ញៗ ទំនៀមអ្នកស្រុក ប្រារព្ធភ្ជាប់នឹងបុរាណដ្ឋាន ឬ

---

[៧] មៀច ប៉ុណ្ណ ១៩៩៤: ៦៩-៧៦

[៨] គិន សំណាង ២០១១: ៥៩ និង អាំង ជូលាន ២០១៦: ១០៤-១០៦

[៩] សូមអាន៖ https://www.yosothor.org/publications/khmer-renaissance/chapter-two/chhlong-chet.html

[១០] សូមអាន៖ https://ams.com.kh/khmercivilization/?p=30051

[១១] សូមអាន៖ https://www.yosothor.org/publications/khmer-renaissance/chapter-two/2-75.html

[១២] សូមអាន៖ https://www.yosothor.org/publications/khmer-renaissance/chapter-two/phity-som-terk-pleang-mouy-beb.html

[១៣] សូមអាន៖ https://ams.com.kh/khmercivilization/detail/20982

[១៤] សូមអាន៖ https://ams.com.kh/khmercivilization/detail/19452

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

កន្លែងគោរពបូជាផ្សេងៗ ហើយខ្លះមានកិច្ចភ្ជាប់នឹងព្រះពុទ្ធសាសនា ដោយក្នុងជំនឿសុំទឹកភ្លៀង និងសេចក្តីសុខសម្រាប់ភូមិស្រុក។ ប៉ុន្តែព្រះរាជពិធី ប្រារព្ធក្នុងជំនឿពាក់ព័ន្ធនឹងទឹកភ្លៀងស្រោចស្រពព្រះនគរទាំងមូល៕

## ឯកសារយោង


ចាប ពិន

១៩៦០, *ព្រះរាជពិធីទ្វាទសមាស*, ភាគ៣, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ឈឹម ក្រសេម និង ចាប ពិន

១៩៥១, *ព្រះរាជពិធីទ្វាទសមាស*, ភាគ២, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ពេជ្រ សល់

១៩៦៦, *ពិធីប្រចាំដប់ពីរខែ*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ភិន សំណាង

២០១១, *ស្រូវក្នុងប្រពៃណីខ្មែរ*, នគរវត្ត, ភ្នំពេញ

អាំង ជូលាន

២០១០-២០១១, "ចូលចេត្រ", *កម្រងអត្ថបទក្នុងបណ្តាញពត៌មានវប្បធម៌ខ្មែរ*, លេខ ៦, ទំ.៣២-៣៥, យសោធរ, ភ្នំពេញ

២០១២-២០១៣, "សំពះព្រះខែ" *កម្រងអត្ថបទក្នុងបណ្តាញពត៌មានវប្បធម៌ខ្មែរ*, លេខ៨, ទំ.៣៧-៤២, យសោធរ, ភ្នំពេញ

២០១៦, "អកព្រះខែ", *កម្រងអត្ថបទក្នុងបណ្តាញពត៌មានវប្បធម៌ខ្មែរ*, លេខ១១, ទំ.១០៤-១០៦, យសោធរ, ភ្នំពេញ


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត